ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣ ✻ ៤៤

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ៣៤៧ ធទឧ

# សេចក្តីជូនដំណឹង

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា បន្ទាប់ពីបានធ្វើការសង្កេត តាមដានលើស្ថានភាពអាកាសធាតុរួចមក ឃើញថា : នៅវេលាម៉ោង 01 រំលងអាធ្រាតឈានចូលថ្ងៃទី 5 ខែវិច្ឆិកា ឆ្នាំ 2011 នេះ មានសម្ពាធទាបមួយដែលភ្ជាប់ជាមួយខាងចុងប្រពន្ធ័សម្ពាបទាប ដោយស្ថិតនៅលើសមុទ្រចិនខាងត្បូងត្រង់ភាគអាគ្នេយ៍ប្រទេសវៀតណាម ។ សម្ពាធទាបនេះ កំពុងរំកិលមកទិសពាយ័ព្យ ដែលនឹងមកដល់លើភាគកណ្តាលប្រទេសកម្ពុជា នៅរំលងអាធ្រាតឈានចូលដល់ថ្ងៃទី 07 ខែវិច្ឆិកា ឆ្នាំ 2011 ។ ឥទ្ធិពលនៃសម្ពាធទាបនេះនឹងធ្វើឱ្យមានភ្លៀងធ្លាក់ពីមធ្យមទៅបង្គួរនៅផ្នែកមួយចំនួននាបណ្តារាជធានី ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី 06 ដល់ថ្ងៃទី 08 ខែវិច្ឆិកា ឆ្នាំ 2011 រួមមាន រាជធានីភ្នំពេញ ខេត្តមណ្ឌលគីរី ក្រចេះ កំពង់ធំ ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ស្ពឺ កណ្តាល ព្រៃវែង និងខេត្តស្វាយរៀង ។

យោងតាមស្ថានភាពធាតុអាកាសខាងលើ ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់អាជ្ញាធរដែនដី និងប្រជាពលរដ្ឋដែលរស់នៅតាមបណ្តារាជធានី ខេត្ត ដូចបានជម្រាបជូនខាងលើ ជ្រាបជាព័ត៌មាន និងសូមបញ្ជាក់ជូនថា ស្ថានភាពធ្លាក់ភ្លៀងនេះ គឺជាការធ្លាក់ភ្លៀងធម្មតានៅចុងរដូវវស្សា និងពុំអាចបង្កឱ្យមានជាជំនន់ទឹកភ្លៀង ឬក៏ជះឥទ្ធិពលដល់ការកើនឡើងនៃកំពស់ទឹកទន្លេទេ ។

*រាជធានីភ្នំពេញ ,ថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ ២០១១*

**រដ្ឋមន្ត្រី**

**លឹម គានហោ**

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh